ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

របាយការណ៍
នៃកិច្ចប្រជុំថ្នាក់ដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

នៅថ្ងៃទី ២៩ ខែមករា ឆ្នាំ ២០១៤ វេលាម៉ោង ០៣:០០ នាទីរសៀល នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំកិច្ចប្រជុំមួយ ក្រោមអធិបតីភាព **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រី ទទួលបេសកកម្មពិសេស និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

សមាសភាពចូលរួមក្នុងកិច្ចប្រជុំនេះមាន៖ ឯកឧត្តម លោកជំទាវ ជាអនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឯកឧត្តម លោក លោកស្រី ជាអគ្គលេខាធិការ អគ្គលេខាធិការរង និង ជាប្រធាននាយកដ្ឋានទាំងអស់ ។

អវត្តមាន

ឯកឧត្តមវេជ្ជ. ជា សំអាន អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

គោលបំណងនៃកិច្ចប្រជុំនេះមាន៖

- របាយការណ៍វឌ្ឍនភាព ប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន
- ការពិភាក្សា ផ្តល់យោបល់ ស្តីពីការត្រៀមរៀបចំវិបស្សនា (Retreat) នៅខែ កុម្ភៈ ឆ្នាំ ២០១៤ ។
- របាយការណ៍យុទ្ធសាស្ត្រថ្មី
- សេចក្តីផ្សេងៗ

ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រធានមានប្រសាសន៍ស្វាគមន៍ ដល់ថ្នាក់ដឹកនាំ និង មន្ត្រីទាំងអស់ ដោយបានបញ្ជាក់ពីទឹកចិត្ត ក្នុងនាមជាប្រធានដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ការតាំងចិត្តដើម្បីដឹកនាំ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឲ្យដំណើរការទៅបានប្រសើរ និង មានប្រសិទ្ធភាព ។

១- របាយការណ៍វឌ្ឍនភាពប្រចាំខែ របស់អគ្គលេខាធិការដ្ឋាន (ដោយឯកឧត្តម អគ្គលេខាធិការ) ៖

ការសម្របសម្រួលទូទៅ

- រៀបចំ និង សម្របសម្រួលកិច្ចប្រជុំ ក្នុងការរៀបចំធ្វើផែនការការងារសំរាប់រៀបស្សនា នៅខែកុម្ភៈ ឆ្នាំ ២០១៨ ។
- រៀបចំកិច្ចប្រជុំក្រុមការងារមូលនិធិសាកល (Management Team)
- កិច្ចប្រជុំផ្សព្វផ្សាយអេដស៍ដល់និស្សិតសាលា Guide School ក្រសួងទេសចរណ៍ និង សាកលវិទ្យាល័យ Western ។
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយ ៧ ចំណុចរបស់រាជរដ្ឋាភិបាល ។
- រៀបចំ និង សម្របសម្រួលកិច្ចប្រជុំ GDJ
- រៀបចំធ្វើកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ២០១៥-២០១៧ ដើម្បីជូនទៅក្រសួងផែនការ ។ ក្នុងនោះ អគ្គលេខាធិការដ្ឋាន បានចាត់តាំង ឯកឧត្តមវេជ្ជ. ហោ ប៊ុនឡេង និង លោកស្រីវេជ្ជ. ងិន លីណា ក្នុងការរៀបចំការងារនេះ ជូនទៅក្រសួងផែនការ ។

ចំពោះសកម្មភាព ដែលបានអនុវត្តនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ជាមួយនឹងការកោតសរសើរ ដូចតទៅ ៖

- អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានការងារជាច្រើននៅចំពោះមុខ ដូចនេះ យើងត្រូវតែពង្រឹងសមត្ថភាពមន្ត្រី ។
- រាល់ការប្រជុំ ត្រូវមានរបាយការណ៍ ឬ កំណត់ហេតុ ដែលសរសេរជាភាសាខ្មែរ និង ភាសាអង់គ្លេស ។ របាយការណ៍ ឬ កំណត់ហេតុនេះ ត្រូវបានមួយថ្ងៃ ឬ ពីរថ្ងៃបន្ទាប់ពីប្រជុំរួច ។
- រាល់ការប្រជុំ (ដូចជាប្រជុំ GDJ) ត្រូវមានរបាយការណ៍នៃកិច្ចប្រជុំលើកមុន ដើម្បីដាក់ជូនសមាជិកអង្គប្រជុំចូលរួម ឲ្យបានដឹងពីលទ្ធផល ដែលបានសម្រេចក្នុងអង្គប្រជុំកាលពីលើមុន ដើម្បីងាយស្រួលក្នុងការតាមដានការងារ ។
- ការងារគេហទំព័រ (Website) ត្រូវ Update នូវអ្វីដែលថ្មីៗ ។
- ការងាររដ្ឋបាល ប្រធាននាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ត្រូវពិនិត្យមើលពីការងារបុគ្គលិកកិច្ចសន្យា និង អណ្តែត ដើម្បីឲ្យត្រូវទៅតាមច្បាប់លក្ខន្តិក:មន្ត្រីរាជការ ។
- ចំពោះអ្នកបើកបរសំរាប់ថ្នាក់ដឹកនាំ ឯកឧត្តមទេសរដ្ឋមន្ត្រី មានប្រសាសន៍ថា នឹងរកជូន តែសំរាប់ការឧបត្ថម្ភ សូមថ្នាក់ដឹកនាំនីមួយៗ ជួយឧបត្ថម្ភខ្លះៗផង ។
- បានស្នើធ្វើប្រតិភូកម្មអំណាច ចេញពីក្រសួងសុខាភិបាល ក្នុងការគ្រប់គ្រងមន្ត្រីបុគ្គលិក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ឯកឧត្តមទេសរដ្ឋមន្ត្រី និង ជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និង ទទួលបានតំណែងមួយទៀត គឺប្រធាន Country Coordinating Committee (CCC) ។

ហើយឯកឧត្តម មានគម្រោង នឹងទាញយកការិយាល័យ Secretariat CCC មកដាក់នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

២-ការពិភាក្សា ផ្តល់យោបល់ ស្តីពីការត្រៀមរៀបចំវិបស្សនា (Retreat) នៅខែ កុម្ភៈ ឆ្នាំ ២០១៤

ឯកឧត្តមវេជ្ជ. ទា ផលា បង្ហាញពីគោលបំណងនៃការរៀបចំធ្វើវិបស្សនា(Retreat) ៖

- បង្ហាញឲ្យមន្ត្រីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់ បានដឹងថា ខាងមុខយើងអាចនឹងគ្រប់គ្រងថវិកាទូទាំងប្រទេសលើវិស័យអេដស៍ ដូចនេះមន្ត្រីទាំងអស់ ត្រូវខិតខំប្រឹងប្រែង ពង្រឹងសមត្ថភាពរបស់ខ្លួន ដើម្បីឈានទៅរកការគ្រប់គ្រងថវិកាធំ ។
- ការរៀបចំជាក្រុមការងារចំនួន ៥ ដែលជាឆ្អឹងនៃការរៀបចំ NSPIV 2015-2018 ។ ក្រុមការងារនីមួយៗ គឺនាយកដ្ឋាននីមួយៗ ជាអ្នកសម្របសម្រួល នៅក្នុងក្រុមការងារនីមួយៗនោះ ។
- ក្រុមការងារនីមួយៗ ត្រូវរាយការណ៍ នៅក្នុងកិច្ចប្រជុំ GDJ ពីសកម្មភាពការងារ រយៈពេល ២ ខែម្តង ។
- ការរៀបចំវិបស្សនានេះ គឺនៅខេត្តព្រះសីហនុ

៣-របាយការណ៍យុទ្ធសាស្ត្រថ្មី (បង្ហាញដោយ ឯកឧត្តមវេជ្ជ ទា ផលា) ៖

- បង្កើតជាក្រុមការងារបច្ចេកទេសចំនួន ៥ ដែលជាឆ្អឹងនៃការរៀបចំ NSPIV 2015-2018 ។ ក្រុមការងារនីមួយៗ គឺនាយកដ្ឋាននីមួយៗ ជាអ្នកសម្របសម្រួល នៅក្នុងក្រុមការងារនេះ ។ ក្រុមការងារនេះ មាន ៖
    1. Continuum of Prevention, Care, Treatment and Support
    2. Impact Mitigation
    3. Enabling Environment and HR
    4. Leadership and Development Synergies
    5. M & E
- ក្រុមការងារនីមួយៗ ត្រូវរាយការណ៍ នៅក្នុងកិច្ចប្រជុំ GDJ ពីសកម្មភាពការងារ រយៈពេល ២ ខែម្តង ។

ឯកឧត្តមទេសរដ្ឋមន្ត្រី មានអនុសាសន៍ថា ៖

- ក្រុមការងារនីមួយៗ គួរតែដាក់ឈ្មោះ Technical Working Group of National Strategy Plan ។
- ក្រុមការងារទាំង ៥នេះ នឹងចេញសេចក្តីសម្រេច ក្រោយពីធ្វើវិបស្សនាចប់ ។

- ក្រុមការងារទាំង ៥ នេះ គឺ ឯកឧត្តមវេជ្ជ. ទា ជលា ជាអ្នកសម្របសម្រួលថ្នាក់ជាតិ ។

ការពិភាក្សា

- **ឯកឧត្តមវេជ្ជ មាន ឈីវុន** តំណាងឯកឧត្តម ម៉ម ប៊ុនហេង រដ្ឋមន្ត្រីក្រសួងសុខាភិបាល និង ជាអនុប្រធានទី១ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានលើកឡើងថា៖ ថវិកាមូលនិធិសាកល Phrase II បានចុះហត្ថលេខាហើយ ដែលមានទឹកប្រាក់ជាង ៧១ លានដុល្លា។ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សមល្មមធ្វើជា PR ក្នុងការរៀបចំសម្របសម្រួលនៅអនាគត ។

- **ឯកឧត្តមវេជ្ជ ស៊ឹម គីមសែន** អនុប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានលើកឡើងថា បើបង្កើតក្រុមការងារបច្ចេកទេសចំនួន ៥ នេះ ឡើង គួរតែនិរាករក្រុមការងារចាស់ទាំង ៧ ចោលសិន ។

- **ឯកឧត្តម ឡឹម ពេជ្រពិសី** ទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានលើកឡើងដែលទាក់ទងទៅនឹង Website និង អត្រានៃមេរោគអេដស៍ និង ជំងឺអេដស៍នៅកម្ពុជា

ចុងបញ្ចប់ ឯកឧត្តមប្រធាន បានបញ្ចប់នូវកិច្ចប្រជុំ នៅវេលាម៉ោង ១១:០០នាទី នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាស សាមគ្គីភាព និង ទទួលខុសត្រូវខ្ពស់។

ថ្ងៃទី ៣០ ខែ មករា ឆ្នាំ២០១៤

អគ្គលេខាធិការ

ឯកឧត្តមវេជ្ជ តែង គង្គី